ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៣ ស្តីពី :

១-ត្រូវបានតែងតាំងឯកឧត្តម ហ៊ុន យ៉ាន់ ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ អគ្គនាយក ។

២-ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៨/៨០៨ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងឯកឧត្តម គីម យ៉ុងហ្សុត ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើ អគ្គនាយក ត្រូវចាត់ទុកជានិរាករណ៍ ៥៦៥៤

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៤ ស្តីពីការតម្លើងថ្នាក់តាមសញ្ញាបត្រក្នុង ឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃជូនមន្ត្រីរាជការស៊ីវិល ចំនួន ០២ រូប ៥៦៥៥

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៦ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០៣ រូប អោយបំពេញមុខងារជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ អគ្គនាយក ៥៦៥៦

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៧ ស្តីពីការតម្លើង ឋានន្តរស័ក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈជូនលោក ម៉ែន ផាត ពីវរមន្ត្រីថ្នាក់លេខ ៤ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ៥៦៥៧

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៦៨ ស្តីពីការតម្លើង ឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៥៦៥៨

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៥ ស្តីពីការតម្លើង ឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៧ រូប ៥៦៥៩

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៦ ស្តីពីការតែងតាំងឯកឧត្តម ជា ថុន ជា ឧកញ៉ា ៥៦៦០

០១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៧៩ ស្តីពីការតែងតាំងទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ចំនួន ០៣ រូប ៥៦៦១

០៤-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៧៨១ ស្តីពីការតែងតាំងឯកឧត្តម ស្រ៊ុន គុន្ធុល ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា សម្រាប់នីតិកាលទី ២ មានឋានៈស្មើ រដ្ឋលេខាធិការ ៥៦៦២

០៤-ឧ-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០ឧ០៩/៧ឧ២ ស្តីពីការតម្លើង ឋានៈជូន ឯកឧត្តម ចំនួន ០២ រូប បច្ចុប្បន្នជាទីប្រឹក្សាឯកឧត្តម **ខួន ញ៉ិល** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៤ ៥៦៦៣

០៧-ឧ-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០ឧ០៩/៧៩០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និង អស់លោក ចំនួន ២២ រូប ៥៦៦៤

០៧-ឧ-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០ឧ០៩/៧៩២ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ អស់លោក និង នាយទាហានជាន់ខ្ពស់ ចំនួន ២៤ រូប ៥៦៦៦

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៥-ឧ-២០០៩ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និង កាកសំណល់សង្គ្រាម ៥៦៦ឧ

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១១៩ឧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦ឧ៨

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១១៩ឧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៦ឧ៩

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១១៩៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៦៨០

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥ឧ២៣

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥ឧ២៥

០ឧ-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥ឧ២ឧ

០៩-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០៣ អនក្រ.តត ស្តីពីការតម្លើងឋានៈជូនមន្ត្រីរាជការ ៥ឧ៣០

០៩-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥ឧ៣២

២០-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥ឧ៣៣

២១-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០៦ អនក្រ.តត ស្តីពីការបំពេញបន្ថែមសមាសភាពក្នុងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ៥ឧ៣៤

២១-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០ឧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥ឧ៣៦

២១-ឧ-២០០៩ -អនុក្រឹត្យលេខ ១២០៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥ឧ៣៨

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២០-១១-២០០៨ -លិខិតបញ្ជាក់លេខ ៦០៤០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយស៍ គិច ខូ អិលធីឌី** ៥ឧ៣៩

ត

២០-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៤១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៉ែត្រាហ្គោល អ៊ិនវេសមេន ត្រូប**	៥៧៤១
២០-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៤៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថេ ស៊ី ខេ ស៊ី**	៥៧៤៣
២០-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៤៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេធលឡាញ ម៉ាញនីង ខមភេនី**	៥៧៤៥
២០-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៤៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោល អេន ត្រូប (ខេមបូឌា)**	៥៧៤៧
២១-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៤៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិលអិនអិល (ខេមបូឌា) ខូ អិលធីឌី**	៥៧៤៩
២១-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៥០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូ-ហ្វាញ ឌីហ្សាញ & អេនជីនារីង**	៥៧៥១
២១-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៥៣ ពណ.ចបព ស្តីពីការទទួលចុះបញ្ជីនូវការបង្កើតការិយាល័យ តំណាងពាណិជ្ជកម្ម នៃក្រុមហ៊ុន **នីគូគិច យ៉ញ ស្ពុត ខមភេនី** ហៅ **នីគូគិច (ខេមបូឌា)** ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេសវៀតណាម	៥៧៥៣
២១-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៧០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យេផេង ផេភើរ ត្រាហ្វ ថេសិន**	៥៧៥៤
២៤-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៧១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយហ្វ៍ ខេមហាន**	៥៧៥៦
២៤-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៧២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ.ជី.ប៊ី.អាយ ថេត**	៥៧៥៨
២៤-១១-២០០៨	-លិខិតបញ្ជាក់លេខ ៦០៧៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន អយល៍ សីបផត សីឌីស**	៥៧៦០

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៨៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហានភូមិជាតិសាសនា រតនកត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាគ្សត្រ
ខេមរាជនា សម្ងហោតាស តម្ពុជឯករាជ្ជបួរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរស្រីពិរាស្ត្រ ព្រះចៅក្រុងតម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ហ៊ុន យ៉ង់** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានឋានៈស្មើអគ្គនាយក ។

មាត្រា ២ : ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៨/ ៨០៨ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **គីម យ៉ុងហ៊ុក** ជាទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយ មានឋានៈ ស្មើអគ្គនាយក ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

លេខ: ៧២៧ ច.ល

ស្មើនឹងច្បាប់ចម្លងចែក
ភ្នំពេញ, ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ២០០៩
អគ្គលេខាធិការរដ្ឋាភិបាល

ជាំ ឌីនកែន

៣រល.០៩០៩.៧៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦តរាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបូលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលកូន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលកូន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្ទាប់

មាត្រា ១ : ត្រូវបានតម្លើងថ្នាក់តាមសញ្ញាបត្រក្នុង **ឋានន្តរស័ក្តិ ឧត្តមមន្ត្រី** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការស៊ីវិល ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១ - ឯកឧត្តម **អង មង្គល** ពី ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៣

២ - ឯកឧត្តម **សេង យូអាន់** ពី ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៦ ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ។

មាត្រា ២ : ប្យៀវត្សមូលដ្ឋានត្រូវបានអនុវត្តគិតចាប់ពីថ្ងៃចេញព្រះរាជក្រឹត្យនេះ ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងតាមវេនអតីតភាពឱ្យនៅដដែល ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្ឌឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៣៦៧៨ ច.ល

ប្រើប្រាស្រមួងចែក

ភ្នំពេញ ថ្ងៃទី ៤៣ ខែ ៧៣ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ត្រឹនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

ព្រះរាជាណាចក្រកម្ពុជា

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៤៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា អគ្គតន្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ០៣ រូប អោយបំពេញមុខងារដូចតទៅ :

១-ឯកឧត្តម **សូ សុភ័ទ្ធ** ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ **អគ្គនាយក**

២-ឯកឧត្តម **ខាត់ បុត្តកុសល** ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ **អគ្គនាយក**

៣-ឯកឧត្តម **អាន ពេជ្រហត្ថជា** ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជកររ
នរោត្តម សីហមុនី

៣រល. ០៩០៨. ៧៧៧

លេខ: ៧២៤.ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

ចម្លងជូនដើម្បីចូលបម្រើការងារ
ភ្នំពេញ, ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ២០០៩
អគ្គលេខាធិការរដ្ឋាភិបាល

ជិន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រកូតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិកិត្តិយសជាកិច្ចបច្ចាមរណៈជូនលោក **ទ៉ែន ផាត** ពីវរមន្ត្រីថ្នាក់លេខ ៤ ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជការ
នរោត្តម សីហមុនី

លេខ: ៧៦៦ ច.ល
ជៃម្ឋីបម្ជងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៩
មន្ត្រីលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រកូតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ឯក

- លោកឧត្តមសេនីយ៍ទោ **លន់ ណេត** អត្តលេខ ០០៥៤ ។

ខ-ថ្នាក់ឧត្តមសេនីយ៍ទោ

- លោកឧត្តមសេនីយ៍ត្រី **ណឹម សាមុត** អត្តលេខ ០១៩១ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៧៤ ច.ល

ជៃម្លីបម្លងចែក

ភាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០៩

ទ្រឹតាលេខាធិការនៃរាជរដ្ឋាភិបាល

៣៧៧.០៩០៩.៧៧៩

ធ្វើនៅព្រះបរមរាជវាំង ភាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦តរាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្ទាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម :

ក-ថ្នាក់ឧត្តមសេនីយ៍ទោ :

១-លោកឧត្តមសេនីយ៍ត្រី	**សោម សុភាព**	អត្តលេខ ០២៩៧
២-លោកឧត្តមសេនីយ៍ត្រី	**ខេង សុមេធ**	អត្តលេខ ០៧២៧១ ។

ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី :

១-លោកវរសេនីយ៍ឯក	**ហ៊ុម យ៉ាន**	អត្តលេខ ០២៣០៥
២-លោកវរសេនីយ៍ឯក	**ឌី ចិជ្ជា**	អត្តលេខ ០១២៧៨
៣-លោកវរសេនីយ៍ឯក	**ថន ប៉ូច**	អត្តលេខ ៦១៧៣១
៤-លោកវរសេនីយ៍ឯក	**លីម ឌុង**	អត្តលេខ ០៩៦៥
៥-លោកវរសេនីយ៍ឯក	**ផាន់ សុផេង**	អត្តលេខ ០៤៩៥ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានស់រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៩០៧.៧៧៦

លេខ: ៣៤៤ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៧៤ ខែ ៨៧ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

ឃន ជិនកេន

ព្រះរាជក្រឹត្យ

ឧស/រតត/០៨០៩/៧៧៨

យើង

ព្រះតរុណោព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតូតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៧តរាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម ជា ថុង

ជា

ឧកញ៉ា

៣រល.០៩០៤.៧៤៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៤៣ច.ល

ជើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០០៩
រដ្ឋលេខាធិការរាជរដ្ឋាភិបាល

ឃ្លាំ ខិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៧៩ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាទឥដ្ឋិយា ទេមរាជ្ជានុស្ត្រ ឫទ្ធិន្ទ្រាធរាមហាឥស្សរ
ទេមរាជានា សម្ងហោរាស អគ្គជាឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ទេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើត ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ចំនួន ០៣ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **យ៉ីម ដុង** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម **យ៉ាន់ ទ៉ាន់យ៉ង់** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម **សំ សារ៉ាត** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបាន សម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ត្រឹមភាពដើមប្លន់ចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០៩
ប្រធានលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

ត.រ.ល.ព.ន.ស.០៩០៨.៧៩០ លេខ: ៧២៩ច.ល

ថ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៩១ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាឥស្តិយា ខេមរាជ្ជាអ្រស្ត្រ ពុទ្ធិឡ្ហាធរមហាក្សត្រ
ខេមរាជនា សមូហោភាស តម្កុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងតម្កុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ក្រាសំបថ្លាប់

មាត្រា១: តែងតាំងឯកឧត្តម **ស្ត៊ុន គុន្ធុល** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជការ
នរោត្តម សីហមុនី

៣រល.០៩០៩.៧៩២

លេខ: ៧៣១ ច.ល
ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៩ **ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១២ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាត្សត្រ
ខេមរាជនា សមូហោភាស កម្ពុជាឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលបានប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម **ងួន ញ៉ុល** ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.- ត្រូវបានតម្លើងឋានៈជូន :

១/-ឯកឧត្តម **សេង សុជាតិ** បច្ចុប្បន្នជាទីប្រឹក្សាឯកឧត្តម **ងួន ញ៉ុល** អនុប្រធានទី១រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **រដ្ឋលេខាធិការ**

២/-ឯកឧត្តម **ជា គឹមហន** បច្ចុប្បន្នជាទីប្រឹក្សាឯកឧត្តម **ងួន ញ៉ុល** អនុប្រធានទី១រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន**

មាត្រា២.- សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ស.០៩០៩.៧៩៣

លេខ: ៧៣០ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឯ ឆ្នាំ ២០០៩
រដ្ឋលេខាធិការរងរាជរដ្ឋាភិបាល

ឃ្លុន ឌិនកេន

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីចិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-ត្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរ៉ីចឌ្ឍន៍** ចំពោះ :

- ១- ឯកឧត្តម **គាំង** **គុងហ៊ាង**
- ២- ឯកឧត្តម **គើត** **សេគាណូ**
- ៣- ឯកឧត្តម **គីម** **ចណ្ឌា**
- ៤- លោក **នី** **ស្ទីចូត្តា**
- ៥- លោក **គើត** **ជាវ៉ាស្ទី**

ខ-ត្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

- ១- លោក **ឃី** **សុខា**
- ២- លោក **ប៊ុន** **ជា**
- ៣- លោក **ស្ទិន** **ជាវ៉ាស្ទី**

គ-ត្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឧន្ន** ចំពោះ :

- ១- លោក **ហាស្សាន់** **ប៉ាស្សារី**
- ២- លោកទន្តបណ្ឌិត **សរ** **សុខូន**
- ៣- លោក **ប្រាត់** **គាវ៉ាចូធ**

ឃ-ត្រឿងឥស្សរិយយស **សហមេត្រ៉ី** ថ្នាក់ **សេនា** ចំពោះ :

- ១- Mr.HAJI MOHAMAD AMIN BIN HASHIM
- ២- DR. ABDUL AZIZ BIN AZIMULLAH
- ៣- Mr. HAJI ABDUL HAMID BIN HAJI BAWAL
- ៤- Mr. TUAN SUHAIMI BIN BADRUL JAMIL
- ៥- Mr. TUAN HAJI FATHIL BIN ISMAIL
- ៦- Mr. AIMI AIZAL BIN NASHARUDDIN
- ៧- Mr. CIKGU MOHAMAD AZMI BIN ABDUL AZIZ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៨- Mr. TUAN HAJI MOHAMAD AZHAM BIN ISMAIL

៩- Mr. TUAN HAJI ROSLI TUANKU SITI RAUDZOH

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរិទ្ធ ចំពោះ :

១- លោក អំ ឫទ្ធលី ២- លោក ម៉ែន សិរី

៣៧.០៩០៨.៨០១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៣៣ ច.ល
ជើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ឃុន ជិនកេន

ន្ស/រកត/០៨០៩/៧៩៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រកូតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សីរីទិបុលា ខេមរាស្រីពិ៉រាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ឆ្លោសព្រះរាជទាន

ទូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

ឧត្តមសេនីយ៍ត្រី	ឡេង ប៊ុន្នី	០០០៤៥២

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១-លោក	ហេង ស៊ុន្យើន
២-លោក	សូន ជារ៉ារិទ្ធ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

១-វរសេនីយ៍ឯក	ធន់ ឌ្យើន	០០២១០៣
២-វរសេនីយ៍ទោ	ឡីក ជាន់ណា	០៥០២៥៩
៣-វរសេនីយ៍ទោ	ជូប សុតំណូ	០២២២៦៦

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សបូទ្ធិ ចំពោះ :-

១-វរសេនីយ៍ឯក	អ៊ុំ ឌីណា	០៤៦០៨០
២-វរសេនីយ៍ឯក	មុំ នាង	០០៤៧៣៤
៣-វរសេនីយ៍ឯក	ពេជ្ជ ស្រស់	០១៦៧៤៨
៤-វរសេនីយ៍ឯក	ជា ស្រេង	០០៤៨៩៨
៥-វរសេនីយ៍ឯក	ខីម ធិញ	០០៣៤០២
៦-វរសេនីយ៍ឯក	សៅ សាម្យើន	០០៤៤៤៦៣
៧-វរសេនីយ៍ឯក	ហ៊ុល ប៊ុនធ្យើន	០០៥៥៦៦
៨-វរសេនីយ៍ទោ	យ៉ាន សុខន	០២១៧៦៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៩-វរសេនីយ៍ទោ	សុន	ថាវ៉ី	០១៦៤៥៣
១០-វរសេនីយ៍ទោ	ម៉ៃ	ធារិទ្ធ	០០១៣៥១
១១-វរសេនីយ៍ទោ	ហ៊ីម	សារ៉ឿន	០២៧៤៨៥
១២-វរសេនីយ៍ទោ	រ៉ត្ន	កុសល	០១៧៦៤៤
១៣-វរសេនីយ៍ទោ	កេត	សំអ៊ឿន	០១៧៦២២
១៤-វរសេនីយ៍ទោ	ពេជ្ជ	ឫុធ	០២៧១៤៣
១៥-វរសេនីយ៍ទោ	សេង	សុផល	០១៧៦២១
១៦-វរសេនីយ៍ទោ	មាស	សារ៉ុម	០១៩៣៤៤
១៧-វរសេនីយ៍ទោ	សួន	ចាន់ថា	០០២១២៦
១៨-វរសេនីយ៍ទោ	អ៊ុក	ម៉ុនធ៊ឿន	០១៦៤៦៤

៣៧៧.០៩០៧.៧០៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៤៥.ច.ល
ឈ្មៀមម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឆ្លាំ ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ឌិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកែសម្រួល និងតម្លើងមជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងបណ្តុះបណ្តាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ។

មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ហៅកាត់ថា " ម.ជ.រ.ប.ក. " ភាសាអង់គ្លេសសរសេរថា " NATIONAL CENTER FOR PEACEKEEPING FORCE, MINE AND EXPLOSIVE REMNANTS OF WAR CLEARANCE " ហៅកាត់ថា " **N P M E C** " ។

ជំពូកទី ២
តួនាទី និងភារកិច្ច

មាត្រា ២.-

ម.ជ.រ.ប.ក. ជាមជ្ឈមណ្ឌលជាតិតែមួយគត់ ដែលមានតួនាទីបំពេញកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

មាត្រា ៣.-

ម.ជ.រ.ប.ក. មានភារកិច្ចដូចតទៅ:

- រៀបចំផែនការយុទ្ធសាស្ត្រយៈពេលវែង មធ្យម ខ្លី របស់ ម.ជ.រ.ប.ក. លើវិស័យបោសសំអាតមីន កាកសំណល់សង្គ្រាម និងរក្សាសន្តិភាពសកល
- រៀបចំផែនការប្រតិបត្តិការបោសសំអាតមីន និងរក្សាសន្តិភាពសកល ដែលមាន រក្សាសណ្តាប់ធ្នាប់សាធារណៈ សង្កេតការណ៍យោធា កិច្ចការរដ្ឋបាល គ្រោះមហន្តរាយ និងបណ្តាការងារផ្សេងទៀតដែលពាក់ព័ន្ធនឹងការចូលរួមថែរក្សាសន្តិភាពអង្គការសហប្រជាជាតិ
- រៀបចំហ្វឹកហ្វឺន បណ្តុះបណ្តាល និងសិក្សាស្រាវជ្រាវ ពិនិត្យវិជ្ជាជីវៈ បច្ចេកទេស និងបទដ្ឋានប្រតិបត្តិការនានា លើគ្រប់ផ្នែក-ជំនាញ និងភាសារបរទេស ដែលពាក់ព័ន្ធទៅនឹងការងារបោសសំអាតមីន និងរក្សាសន្តិភាព តាមតំរូវការចាំបាច់
- ហ្វឹកហ្វឺនគ្រប់កងកម្លាំងទាំងអស់មកពីអង្គភាពនានានៃកងយោធពលខេមរភូមិន្ទ ឬមកពីបណ្តាប្រទេសដទៃ ដែលត្រៀមចូលរួមប្រតិបត្តិការរក្សាសន្តិភាពលើផ្នែករក្សាសណ្តាប់ធ្នាប់សាធារណៈ សង្កេតការណ៍យោធា កិច្ចការរដ្ឋបាល គ្រោះមហន្តរាយ និងបោសសំអាតមីន សមស្របតាមភូមិសាស្ត្រនីមួយៗ និងទៅតាមស្តង់ដាបច្ចេកទេសរបស់អង្គការសហប្រជាជាតិ
- រៀបចំនីតិវិធី គោលការណ៍បច្ចេកទេស និងបទប្បញ្ញត្តិផ្សេងៗ លើសកម្មភាពរក្សាសន្តិភាព និងបោសសំអាតមីន
- រៀបចំរចនាសម្ព័ន្ធចាត់តាំងកម្លាំងជំនាញនានា ឯកសារ សម្ភារៈមធ្យោបាយគ្រឿងបំពាក់ តាមស្តង់ដាអង្គការសហប្រជាជាតិ គ្រប់កងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- សិក្សាស្រាវជ្រាវលក្ខណៈភូមិសាស្ត្រ សេដ្ឋកិច្ច នយោបាយរបស់ប្រទេសដែលអង្គការសហប្រជាជាតិ ស្នើសុំចូលរួមថែរក្សាសន្តិភាព ដើម្បីជ្រើសរើសយកប្រទេសមួយណានោះដែលព្រះរាជាណាចក្រកម្ពុជាអាចចូលរួមបាន ជូនគណៈកម្មាធិការជាតិ និងក្រសួងការពារជាតិ
- សហការជាមួយអាជ្ញាធរមីនកម្ពុជា អង្គការប្រតិបត្តិករនានា និងអង្គការសហប្រជាជាតិ ដើម្បីសិក្សាស្រាវជ្រាវ រៀបចំឯកសារ គ្រប់គ្រង វិភាគប្រៀបធៀបទិន្នន័យ និងទីតាំងចំការមីន អំពីគ្រាប់មីន កាកសំណល់សង្គ្រាម និងផ្សព្វផ្សាយឱ្យយល់ដឹងអំពីការគ្រោះថ្នាក់ដោយសារមីន និងកាកសំណល់សង្គ្រាម ក្នុងប្រទេសនិងប្រទេសដែលមានមីន
- រកប្រភពធនធានមនុស្ស សាស្ត្រាចារ្យ គ្រូជំនាញ និងសម្ភារៈមធ្យោបាយគ្រឿងបំពាក់ សំរាប់បណ្តុះបណ្តាល កសាងធនធានមនុស្ស និងចូលរួមប្រតិបត្តិការរក្សាសន្តិភាព
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់គ្រប់សិក្ខាកាមជាតិ អន្តរជាតិ ដែលបានចូលរួមហ្វឹកហ្វឺនបណ្តុះបណ្តាលផ្នែករក្សាសន្តិភាព និងបោសសំអាតមីន កាកសំណល់សង្គ្រាម
- សិក្សាទិដ្ឋភាពច្បាប់ អនុសញ្ញា និងអនុស្សរណៈផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងកិច្ចការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- សិក្សាសេវាកម្មតំលៃសម្ភារៈ មធ្យោបាយ គ្រឿងបំពាក់ និងប្រាក់ឧបត្ថម្ភនានា ដែលអង្គការសហប្រជាជាតិផ្តល់ជូនពេលទៅបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

- តាមដានការទូទាត់តំលៃសម្ភារៈ មធ្យោបាយ និងគ្រឿងបំពាក់ ដែលត្រូវបានយកទៅប្រើប្រាស់ជាមួយអង្គការសហប្រជាជាតិតាមអនុស្សរណៈ និងតាមដានការទូទាត់ប្រាក់ឧបត្ថម្ភនានាពីអង្គការសហប្រជាជាតិ ជូនគណៈកម្មាធិការជាតិ
- ពិនិត្យ និងបំពេញឯកសារសុខភាព បើកគណនី រៀបចំឯកសារ សម្របសម្រួលលិខិតបទដ្ឋាននានា ដល់យោធិនគ្រប់រូបជាមួយបណ្តាក្រសួង ស្ថាប័នរដ្ឋពាក់ព័ន្ធ និងស្ថាប័នជំនាញរបស់អង្គការសហប្រជាជាតិ ដើម្បីបញ្ជូនទៅគណៈកម្មាធិការជាតិសម្របសម្រួល និងក្រសួងការពារជាតិ សំរាប់កងកម្លាំងចេញបំពេញបេសកកម្មរក្សាសន្តិភាព
- សហការក្បែងគរជាមួយបណ្តាប្រទេសនានា ភ្នាក់ងារអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋនានា អាជ្ញាធរពាក់ព័ន្ធ និងភ្នាក់ងារឯកជន ដើម្បីសម្របសម្រួលនិងរកប្រភពជំនួយនូវរាល់មូលដ្ឋាន សម្ភារៈ ឧបករណ៍ មធ្យោបាយគ្រឿងបំពាក់ ថវិកា និងផ្លាស់ប្តូរបទពិសោធន៍ បច្ចេកវិទ្យាទៅវិញទៅមកសំរាប់បំរើឱ្យការងាររក្សាសន្តិភាព និងបោសសំអាតមីន
- លើកយោបល់ ទំនាក់ទំនង ប្រុងប្រៀបការងារ និងសម្របសម្រួលការដឹកជញ្ជូន សម្ភារៈ ចេញ-ចូល ក្នុងប្រទេសក្រៅប្រទេស ជាមួយស្ថាប័នជាតិ-អន្តរជាតិ ដែលសម្ភារៈគ្រឿងបំពាក់ មធ្យោបាយទាំងនោះបំរើឱ្យកិច្ចការរក្សាសន្តិភាព និងបោសសំអាតមីនក្នុងក្របខ័ណ្ឌជាតិ និងអង្គការសហប្រជាជាតិ
- អនុវត្តអនុសញ្ញាអូតាវ៉ាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិតមីនប្រឆាំងមនុស្ស ដែលជាផ្នែកមួយនៃតួនាទីយ៉ាងសំខាន់របស់កងយោធពលខេមរភូមិន្ទ ក្នុងកិច្ចការបោសសំអាតមីន និងកាកសំណល់សង្គ្រាម ដើម្បីរួមចំណែកយ៉ាងខ្លាំងក្លា ទៅលើការស្តារ ការអភិវឌ្ឍន៍ប្រទេសជាតិ រួមមាន ការដោះមីនសំរាប់ស្ថាបនាផ្លូវ ស្ពាន និងដីតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋ
- ចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ត្រួតពិនិត្យការងារ ការធានាសុវត្ថិភាពកំរិតខ្ពស់ឱ្យដល់កងកម្លាំងគ្រប់កងឯកភាព នៃកងយោធពលខេមរភូមិន្ទ ដែលកំពុងធ្វើសកម្មភាពបោសសំអាតមីន កាកសំណល់សង្គ្រាម និងរក្សាសន្តិភាព ដែលថ្នាក់លើប្រគល់ឱ្យ
- គ្រប់គ្រងរំសេវ ជាតិផ្ទុះ អាវុធគ្រប់ប្រភេទក្នុងក្របខណ្ឌរបស់ខ្លួន សំរាប់បំរើឱ្យវិស័យរក្សាសន្តិភាព និងបោសសំអាតមីន កាកសំណល់សង្គ្រាមនៃកងយោធពលខេមរភូមិន្ទ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រសួងការពារជាតិ និង/ឬ គណៈកម្មាធិការជាតិ ប្រគល់ឱ្យ ។

ជំពូកទី ៣
រចនាសម្ព័ន្ធ និងការគ្រប់គ្រង

មាត្រា ៤.-

ម.ជ.រ.ប.ក. មានរចនាសម្ព័ន្ធ ដូចតទៅ :

- លេខាធិការដ្ឋាន
- ជំនាញគ្រប់គ្រង ធនធានមនុស្ស និងបណ្តុះបណ្តាល
- ជំនាញគ្រប់គ្រង ភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល
- ជំនាញគ្រប់គ្រង ស្តង់ដាសម្ភារៈ និងបច្ចេកទេស
- នាយកដ្ឋានផែនការ ប្រតិបត្តិការ និងហ្វឹកហ្វឺន
- នាយកដ្ឋានស្រាវជ្រាវ ទិន្នន័យ និងវិស្វកម្ម
- នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័ត៌មាន
- នាយកដ្ឋានទំនាក់ទំនង សហប្រតិបត្តិការ រក្សាសន្តិភាព និងនីតិកម្ម
- វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាល កងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម ។

អង្គការលេខ នៃ ម.ជ.រ.ប.ក. ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ៥.-

លេខាធិការដ្ឋាន មានតួនាទី និងភារកិច្ច ដូចតទៅ :

- សិក្សាស្រាវជ្រាវ គ្រប់គ្រងលិខិតបទដ្ឋាន ឯកសាររដ្ឋបាលផ្សេងៗ និងតាមដានការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិនានា
- សម្របសម្រួល ទំនាក់ទំនង កិច្ចការរដ្ឋបាល លិខិតបទដ្ឋាន ជាមួយស្ថាប័ន ក្រសួង អង្គការជាតិ អន្តរជាតិ ដែលពាក់ព័ន្ធ
- រៀបចំកិច្ចប្រជុំ សន្និបាត និងពិធីការផ្សេងៗ
- តម្កល់ ត្រួតពិនិត្យរាល់សំណើ គម្រោងផែនការ លិខិតចេញទៅបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធ ផ្សព្វផ្សាយ ជូនដំណឹង និងកត់ត្រា ទទួល បញ្ជូន នូវរាល់ឯកសារ ចេញ-ចូលទាំងអស់
- ពិនិត្យឯកសាររបស់អង្គភាពចំណុះ នៃមជ្ឈមណ្ឌលជាតិ ដើម្បីដាក់ជូនអគ្គនាយកពិនិត្យ និងសំរេច
- ប្រមូលផ្តុំឯកសារកិច្ចព្រមព្រៀង កំណត់ហេតុ វបាយការណ៍ និងអនុសាសន៍របស់ថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

លេខាធិការដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

មាត្រា ៦.-

ជំនាញគ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាល មានតួនាទី និងភារកិច្ចដូចតទៅ :

- រៀបចំរចនាសម្ព័ន្ធចាត់តាំងរបស់លេខាធិការដ្ឋាន, ជំនាញគ្រប់គ្រង, នាយកដ្ឋាន និង វិទ្យាស្ថាន
- សិក្សាស្រាវជ្រាវរាល់ក្របខ័ណ្ឌរចនាសម្ព័ន្ធចាត់តាំងជាតិ អន្តរជាតិ តាមបណ្តាប្រទេសនីមួយៗ ដែលពាក់ព័ន្ធនឹងកម្ពុជា និងអង្គការសហប្រជាជាតិ សំរាប់ការចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- រៀបចំរចនាសម្ព័ន្ធចាត់តាំងតាមជំនាញនីមួយៗ សំរាប់កងកម្លាំងត្រៀមបំរុងចេញបំពេញបេសកកម្មរក្សាសន្តិភាព តាមបទបញ្ជារបស់មជ្ឈមណ្ឌលជាតិ
- បង្កប្រភព រៀបចំឯកសារពាក់ព័ន្ធនានារបស់យោធិន សំបុត្រលក្របខ័ណ្ឌថ្មី ក្នុងកងយោធពលខេមរភូមិន្ទ តាមការសំរេចរបស់ក្រសួងការពារជាតិ និងរាជរដ្ឋាភិបាល សំរាប់ការចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជូនមជ្ឈមណ្ឌលជាតិ
- រៀបចំបែបបទសំណុំលិខិតតែងតាំងផ្លាស់ប្តូរមុខងារ តម្លើងឋានន្តរសក្តិ ជូនរង្វាន់ លិខិតសរសើរ ប័ណ្ណសរសើរ គ្រឿងឥស្សរិយយស តួនាទី និងមុខងារយោធិនតាមស្នាដៃ ជូនកងឯកភាព បុគ្គល ប្រភេទទ័ព ទ័ពជំនាញ ដែលពាក់ព័ន្ធនឹងរក្សាសន្តិភាព និងបោសសំអាតមីន
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សដល់កងកំលាំងគ្រប់ប្រភេទនៅក្នុង និងក្រៅប្រទេស លើគ្រប់ផ្នែក-ជំនាញ និងភាសារបរទេស ដើម្បីធានាបាននូវធនធានមនុស្សគ្រប់គ្រាន់ សំរាប់ចូលរួមប្រតិបត្តិការរក្សាសន្តិភាព
- សម្របសម្រួល ទំនាក់ទំនង បង្កប្រភពធនធានមនុស្សឱ្យមានគ្រប់គ្រាន់ ធានាការប្រើប្រាស់តាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងកិច្ចការរក្សាសន្តិភាពជាមួយស្ថាប័នពាក់ព័ន្ធជាតិ និងអង្គការសហប្រជាជាតិ
- គ្រប់គ្រង ត្រួតពិនិត្យ និងបូកសរុបទិន្នន័យ វបាយការណ៍ ស្ថិតិចំនួនទ័ព នាយទាហាន មន្ត្រី បុគ្គលិក និងយោធិន ចេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជូនមជ្ឈមណ្ឌលជាតិ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

ជំនាញគ្រប់គ្រងនេះ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

មាត្រា ៧.-

ជំនាញគ្រប់គ្រងភស្តុភារ ហិរញ្ញវត្ថុ និងសុខាភិបាល មានតួនាទី និងភារកិច្ច ដូចតទៅ :

- គ្រប់គ្រង បើកចែកប្រាក់ប្សៀវត្សរ៍ ស្បៀង បរិក្ខារ និងគ្រឿងឧបភោគ បរិភោគ ជូនដល់យោធិន មន្ត្រី និងបុគ្គលិក
- សិក្សាស្រាវជ្រាវ រាល់គោលរបបនានារបស់អង្គការសហប្រជាជាតិ សំរាប់ឧបត្ថម្ភដល់នាយទាហាន មន្ត្រី បុគ្គលិក កងកម្លាំងចូលរួមបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- ធ្វើផែនការ និងអនុវត្តគំរោងថវិកាប្រចាំឆ្នាំ
- សម្របសម្រួល ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការជាតិ-អន្តរជាតិនានា លើការងារជំនាញ តាមដានការទូទាត់តំលៃសេវាកម្ម ប្រាក់ឧបត្ថម្ភប្រចាំ ខែ ត្រីមាស ប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិ ជូនមជ្ឈមណ្ឌលជាតិ
- បើកគណនី ត្រួតពិនិត្យសុខភាព ធានាគ្រឿងបំពាក់បុគ្គលជូនយោធិនគ្រប់រូប សំរាប់បើកចែកប្រាក់ឧបត្ថម្ភ ការធានាសុខភាព ដើម្បីបំពេញលក្ខខណ្ឌនានាតាមស្តង់ដាអង្គការសហប្រជាជាតិ
- តាមដាន ត្រួតពិនិត្យការប្រើប្រាស់ថវិកា សម្ភារៈ និងបរិក្ខាររបស់អង្គភាពដែលទទួលបានពីក្រសួង និងស្ថាប័ននានា
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ ទ្រព្យសកម្ម បញ្ជីសារពើភ័ណ្ឌ ចំណូល ចំណាយផ្សេងៗ
- លើកយោបល់បំភ្លឺអំពីការចំណាយសាច់ប្រាក់ និងគំរោងចំណាយនានារបស់អង្គភាពពាក់ព័ន្ធដែលស្នើសុំ ជូនអគ្គនាយកមជ្ឈមណ្ឌលជាតិ ពិនិត្យ និងសំរេច
- ធ្វើរបាយការណ៍ចំណូល ចំណាយ និងទ្រព្យសកម្ម ដើម្បីឆ្លុះបង្ហាញពីស្ថានភាព ហិរញ្ញវត្ថុរៀងរាល់ខែ
- បិទបញ្ជីគណនេយ្យ និងបញ្ជាក់និយ័តភាពគណនេយ្យប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

ជំនាញគ្រប់គ្រងនេះ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

មាត្រា ៨.-

ជំនាញគ្រប់គ្រងស្តង់ដាសម្ភារៈ និងបច្ចេកទេស មានតួនាទី និងភារកិច្ច ដូចតទៅ :

- គ្រប់គ្រងមធ្យោបាយ សម្ភារៈ និងធ្វើបញ្ជីស្ថិតិប្រវត្តិសំគាល់រថយន្ត គ្រឿងចក្រ ម៉ាស៊ីន ម៉ាស៊ីនរាវមីន ឧបករណ៍បច្ចេកទេសគ្រប់ប្រភេទ រំសេវជាតិផ្ទុះ អាវុធគ្រប់ប្រភេទរបស់មជ្ឈមណ្ឌលជាតិ
- សិក្សាស្រាវជ្រាវរាល់មធ្យោបាយគ្រឿងបំពាក់ ឧបករណ៍ប្រើប្រាស់នានា ដែលមានលក្ខណៈសមស្របតាមបច្ចេកវិទ្យាថ្មី ក្របខ័ណ្ឌបំពាក់ តំលៃ និងកំណត់ឱ្យថាប្រភេទ ពេលវេលានៃការប្រើប្រាស់របស់មធ្យោបាយគ្រឿងបំពាក់ឧបករណ៍ទាំងនោះ ធានាការប្រើប្រាស់ស្របតាមស្តង់ដាអង្គការសហប្រជាជាតិ
- រៀបចំផែនការជួសជុល ថែទាំរាល់មធ្យោបាយ គ្រឿងបំពាក់ ឧបករណ៍ប្រើប្រាស់នានាទៅតាមលក្ខណៈបច្ចេកទេស
- សម្របសម្រួល ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការជាតិ-អន្តរជាតិនានា លើការងារធានាបំពាក់ និងដឹកជញ្ជូនរាល់មធ្យោបាយដល់ប្រតិបត្តិករ សំរាប់ប្រតិបត្តិការរក្សាសន្តិភាព និងបោសសំអាតមីន
- តាមដាន ត្រួតពិនិត្យ ណែនាំការប្រើប្រាស់ និងការថែទាំមធ្យោបាយ គ្រឿងបំពាក់ គ្រឿងឧបទេស អាវុធយុទ្ធភ័ណ្ឌគ្រប់ប្រភេទ ដែលរក្សាទុកក្នុងឃ្លាំង និងបំពាក់តាមកងឯកភាពនានាសំរាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការក្នុងប្រទេស និងអង្គការសហប្រជាជាតិ ឱ្យត្រូវតាមលក្ខណៈបច្ចេកទេស
- រៀបចំឯកសារហ្វឹកហ្វឺន បទដ្ឋានបច្ចេកទេស ប្រើប្រាស់មធ្យោបាយគ្រឿងបំពាក់ ម៉ាស៊ីនរាវមីន ដែលទំនើបនានាតាមស្តង់ដាជាតិ និងអង្គការសហប្រជាជាតិ ជូនដល់កងយោធពលខេមរភូមិន្ទ សំរាប់ចេញបំពេញបេសកកម្មក្នុងប្រទេស និងអង្គការសហប្រជាជាតិ
- តាមដានការទូទាត់តំលៃសេវាកម្មរបស់អង្គការសហប្រជាជាតិ លើការប្រើប្រាស់មធ្យោបាយគ្រឿងបំពាក់ និងអាវុធ

គ្រប់ប្រភេទ ពេលបំពេញបេសកកម្មអង្គការសហប្រជាជាតិ
- ធ្វើរបាយការណ៍គុណភាពនូវរាល់មធ្យោបាយ សម្ភារៈ គ្រឿងបំពាក់ ប្រើប្រាស់ ប្រចាំខែ ត្រីមាស និងឆ្នាំ ដែលបានយកទៅប្រើប្រាស់ក្នុងការបំពេញភារកិច្ចរបស់អង្គការសហប្រជាជាតិ
- បំពេញភារកិច្ចផ្សេង១ទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

ជំនាញគ្រប់គ្រងនេះ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយអនុប្រធានមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

មាត្រា ៩.-

នាយកដ្ឋានផែនការ ប្រតិបត្តិការ·និងហ្វឹកហ្វឺន មានតួនាទី និងភារកិច្ច ដូចតទៅ :
- គ្រប់គ្រងកងកម្លាំង ដឹកនាំបញ្ជា ហ្វឹកហ្វឺន កសាងធនធានមនុស្ស សមស្របតាមស្តង់ដាអង្គការសហប្រជាជាតិ
- សម្របសម្រួល ទំនាក់ទំនងជាមួយស្ថាប័ន ក្រសួង មន្ទីរដែលពាក់ព័ន្ធលើការងារហ្វឹកហ្វឺន និងប្រតិបត្តិការបោសសំអាតមីន រក្សាសន្តិភាព ទាំងក្នុងប្រទេស និងអង្គការសហប្រជាជាតិ
- រៀបចំផែនការ កសាងគ្រប់កងកម្លាំង ទាំងផ្នែកថ្នាក់យុទ្ធសាស្ត្រ ផ្នែកយុទ្ធវិធី ឱ្យស្របតាមស្តង់ដាជាតិ អន្តរជាតិ សំរាប់ការចូលរួមប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- រៀបចំផែនការ ហ្វឹកហ្វឺនបំប៉នកងកម្លាំងគ្រប់ប្រភេទ សំរាប់ធានាដល់ការកសាងសមត្ថភាពលើជំនាញរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម
- ត្រៀម និងរៀបចំកងកម្លាំងមានសមត្ថភាពគ្រប់ជំនាញទាំងអស់ដែលអង្គការសហប្រជាជាតិត្រូវការ សំរាប់ចេញបំពេញបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ
- សិក្សា និងកែសំរួលបទដ្ឋានប្រតិបត្តិការផ្សេង១របស់មជ្ឈមណ្ឌលជាតិ លើវិស័យបោសសំអាតមីន និងរក្សាសន្តិភាព សំរាប់ការអនុវត្តបានសំរេចតាមគោលដៅ ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព
- គ្រប់គ្រងជាតិផ្ទុះ គ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះគ្រប់ប្រភេទ ដែលរកឃើញ និងកំទេចតាមការដ្ឋាន
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការអនុវត្តប្រចាំឆ្នាំ
- សហការជាមួយបណ្តាអង្គការ និងប្រតិបត្តិករដោះមីននានា ដែលត្រូវបានទទួលអាជ្ញាប័ណ្ណពីអាជ្ញាធរមីនកម្ពុជា ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ក្នុងកិច្ចការសកម្មភាពមីន
- ទំនាក់ទំនងជាមួយប្រទេសនានា ភ្នាក់ងារអភិវឌ្ឍន៍ជាតិ អន្តរជាតិ ស្ថាប័នរដ្ឋ អាជ្ញាធរពាក់ព័ន្ធ និងម្ចាស់ជំនួយ ដើម្បីរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ ធានាឱ្យការងារប្រតិបត្តិការមានប្រសិទ្ធភាព និងការីរកចំរើនជឿនលឿនដល់គំរោងការអភិវឌ្ឍន៍ក្នុងប្រទេស
- បូកសរុបរបាយការណ៍សកម្មភាព លទ្ធផល ក្នុង និងក្រៅប្រទេសរបស់កងកម្លាំងប្រតិបត្តិការ ទាំងអស់ ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេង១ទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ។

មាត្រា ១០.-

នាយកដ្ឋានស្រាវជ្រាវ ទិន្នន័យ និងវិស្វកម្ម មានតួនាទី និងភារកិច្ច ដូចតទៅ :
- សិក្សាស្រាវជ្រាវវិធីសាស្ត្រទាំងឡាយដែលនាំមកនូវការអភិវឌ្ឍន៍ ក្នុងប្រព័ន្ធការងាររបស់មជ្ឈមណ្ឌលជាតិ ក្នុងវិស័យបោសសំអាតមីន និងរក្សាសន្តិភាពសកល
- រៀបចំមូលដ្ឋានទិន្នន័យដែលប្រមូលផ្តុំពីលទ្ធផលបោសសំអាតមីន ក្នុងកងយោធពលខេមរភូមិន្ទ ចុះក្នុងបញ្ជី និងរក្សាទុកឱ្យមានសុវត្ថិភាពទាំងក្នុង-ក្រៅប្រទេស និងបញ្ជូនទិន្នន័យនេះ ទៅអាជ្ញាធរមីនកម្ពុជា
- សហការជាមួយភ្នាក់ងារបោសសំអាតមីនទាំងឡាយ ដើម្បីធានាដំណើរការប្រកបដោយគុណភាពនូវការផ្លាស់ប្តូរ

ព័តិមានពីគ្នាទៅវិញទៅមក និងត្រួតពិនិត្យតាមផែនការជាតិ ស្តីពីសកម្មភាពមីន
- រៀបចំនីតិវិធី និងបទដ្ឋានផ្សេងៗក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីធានារាល់ឯកសារ ព្រមទាំងព័តិមានទាំងអស់ ត្រូវរក្សាទុក និងប្រើប្រាស់ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់
- រៀបចំហេដ្ឋារចនាសម្ព័ន្ធ សំរាប់កិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ជូនមជ្ឈមណ្ឌលជាតិអំពី ស្ពាន ថ្ពល់ ក្នុងចំការមីន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ។

មាត្រា ១១.-

នាយកដ្ឋានកាកសំណល់សង្គ្រាម គ្រឿងផ្ទុះ និងព័តិមាន មានតួនាទី និងភារកិច្ច ដូចតទៅ :
- សិក្សាស្រាវជ្រាវរកប្រភពព័តិមាននានាពាក់ព័ន្ធនឹងគ្រឿងផ្ទុះសល់ពីសង្គ្រាម គ្រឿងផ្ទុះប្រឆាំងភេវរកម្ម
- សិក្សាស្រាវជ្រាវអំពីយថាប្រភេទគ្រឿងផ្ទុះនានា ដែលសេសសល់ពីសង្គ្រាម ដើម្បីរកវិធីបញ្ឈប់សការគ្រោះថ្នាក់ ឬ កំទេចចោល
- ទំនាក់ទំនងជាមួយភ្នាក់ងារព័តិមានជាតិ និងអន្តរជាតិ ក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរមូលដ្ឋានប្រតិបត្តិការនានា ក្នុងការផ្សព្វផ្សាយអំពីទិសដៅយុទ្ធសាស្ត្រ ផែនការអនុវត្ត និងសកម្មភាពរបស់មជ្ឈមណ្ឌលជាតិ ព្រមទាំងផ្លាស់ប្តូរនូវ បទពិសោធន៍ពីគ្នាទៅវិញទៅមក
- ស្រាវជ្រាវរាល់ទិន្នន័យគ្រឿងផ្ទុះ កាកសំណល់សល់ក្រោយសង្គ្រាម សំរាប់ធ្វើការបោសសំអាត និងកំទេចចោល
- ពិសោធន៍ ស្រាវជ្រាវរាល់របៀបដោះបន្សាប គ្រឿងផ្ទុះ ឱ្យបានត្រឹមត្រូវ ម៉ត់ចត់ ច្បាស់លាស់ទៅតាមលក្ខណៈបច្ចេកទេស មុននឹងប្រគល់ជូនទៅតាមជំនាញអនុវត្តជាក់ស្តែង
- ត្រួតពិនិត្យនូវរាល់សភាពការណ៍ដែលកើតហេតុរួច និងចុះយកព័តិមាន ធ្វើបែបបទ សំណុំឯកសារ ដែលកើតមានឡើង រាយការណ៍ជូនមជ្ឈមណ្ឌលជាតិ
- ផ្សព្វផ្សាយអំពីការគ្រោះថ្នាក់ដោយសារគ្រាប់មីន វិសេវជាតិផ្ទុះ ដែលជាកាកសំណល់សង្គ្រាមដល់ប្រជាពលរដ្ឋ
- ប្រមូលរូបភាព និងវីដេអូ ស្តីពីសកម្មភាពរបស់មជ្ឈមណ្ឌលជាតិ អង្គពិធីថ្នាក់ជាតិ និងអន្តរជាតិផ្សេងៗ
- រៀបចំចងក្រងនូវអត្ថបទ ព័តិមានខ្លី វែង កំណាព្យឱ្យស្របតាមទិសដៅ និងរូបភាព ព្រឹត្តិការណ៍សំខាន់ៗ ដែលទាក់ទង ទៅនឹងសកម្មភាពរបស់មជ្ឈមណ្ឌលជាតិ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ។

មាត្រា ១២.-

នាយកដ្ឋានទំនាក់ទំនង សហប្រតិបត្តិការ រក្សាសន្តិភាព និងនីតិកម្ម មានតួនាទី និងភារកិច្ច ដូចតទៅ :
- សិក្សាស្រាវជ្រាវរាល់នីតិវិធី ច្បាប់ និងបទប្បញ្ញត្តិនានា អនុស្សរណៈ កិច្ចព្រមព្រៀងនានាពាក់ព័ន្ធទៅនឹងកិច្ចការរក្សា សន្តិភាព ធ្វើឱ្យអនុស្សរណៈទាំងនោះសមស្របតាមច្បាប់ជាតិ និងច្បាប់ក្នុងក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ
- រៀបចំឯកសារ និងលិខិតបទដ្ឋាននានាសំរាប់ធ្វើលិខិតឆ្លងដែន និងបំពេញលក្ខខ័ណ្ឌផ្សេងៗរបស់អង្គការសហប្រជាជាតិ សំរាប់កងកំលាំងត្រៀមបំរុងចេញបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ
- ទំនាក់ទំនង និងសហការល្អជាមួយអ្នកជំនាញការជាតិ-អន្តរជាតិ លើការងាររក្សាសន្តិភាព បោសសំអាតមីនមនុស្សធម៌
- ត្រួតពិនិត្យ និងចងក្រងរាល់ឯកសារទាំងឡាយណាដែលទាក់ទងទៅនឹងសកម្មភាពការងាររបស់មជ្ឈមណ្ឌលជាតិ ដើម្បី រៀបចំជាក្បួនខ្នាតសំរាប់ប្រើប្រាស់ និងអនុវត្តការងារ
- តាមដានជាប្រចាំនូវឯកសារផ្នែករក្សាសន្តិភាពក្នុង និងក្រៅប្រទេស ដែលទាក់ទិនទៅលើផ្នែកស៊ីវិល ប៉ូលីស យោធា និងរាយការណ៍ជូនមកមជ្ឈមណ្ឌលជាតិ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

នាយកដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ។

មាត្រា ១៣.-

វិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម នៃ ម.រ.ជ.ប.ក. ហៅកាត់ថា " វ.ហ.រ.ប.ក. " ភាសាអង់គ្លេសសរសេរថា " INSTITUTE FOR PEACEKEEPING FORCE, MINE AND EXPLOSIVE REMNANTS OF WAR CLEARANCE " ហៅកាត់ថា " I P M E C " មានតួនាទី និងភារកិច្ច ដូចតទៅ :

- រៀបចំផែនការ និងហ្វឹកហ្វឺន បណ្តុះបណ្តាលគ្រប់ជំនាញ ក្នុងរយៈពេលវែង មធ្យម ខ្លី ស្របតាមស្តង់ដាជាតិ-អន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងដកបទពិសោធន៍ការអនុវត្តន៍ថ្មីៗដែលសមស្របតាមស្តង់ដារបស់អង្គការសហប្រជាជាតិ
- ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ ដកបទពិសោធន៍ តាមវិទ្យាស្ថាន ស្ថាប័ន និងអង្គភាពនានា
- ទំនាក់ទំនង និងសហការជាមួយបណ្តាវិទ្យាស្ថានហ្វឹកហ្វឺននានា
- វាយតម្លៃការសិក្សារបស់សិក្ខាកាមក្រោយបញ្ចប់វគ្គសិក្សានីមួយៗ ដើម្បីជ្រើសរើសសិក្ខាកាមដែលមានពិន្ទុល្អៗ ធ្វើជាអ្នកផ្តល់បទពិសោធន៍ ដល់សិក្ខាកាមដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់
- សហការជាមួយក្រសួង ស្ថាប័ននានា បណ្តាប្រទេសជាមិត្ត ដើម្បីស្វែងរកគ្រូហ្វឹកហ្វឺនល្អៗ
- ផ្តល់លិខិតបញ្ជាក់ការសិក្សាដល់យោធិនដែលបានបញ្ចប់ការសិក្សា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

វិទ្យាស្ថាន ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន អមដោយនាយករងមួយចំនួន មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន ។

មាត្រា ១៤.-

ក្នុងករណីមានតំរូវការចាំបាច់ ម.ជ.រ.ប.ក. ស្នើសុំគោលការណ៍ជ្រើសរើសជំនាញការជាតិ ឬអន្តរជាតិ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីក្នុងមុខងារសាធារណៈ និងជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ។ លក្ខណៈសម្បត្តិជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា ១៥.-

ម.ជ.រ.ប.ក. មានត្រាមួយដោយឡែក ដើម្បីបំពេញការងាររបស់ខ្លួន ។

រូបសញ្ញាសំគាល់អង្គភាព រូបសញ្ញាសំរាប់បំពាក់លើសំលៀកបំពាក់ និងត្រាបណ្តាអង្គភាពចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា ១៦.-

តួនាទី ភារកិច្ច មុខងារ និងរចនាសម្ព័ន្ធ ចំណុះលេខាធិការដ្ឋាន ជំនាញគ្រប់គ្រងនីមួយៗ នាយកដ្ឋាននីមួយៗ និងវិទ្យាស្ថាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

ជំពូកទី ៤

ប្រភពធនធាន

មាត្រា ១៧.-

ក្រសួងការពារជាតិធានាផ្តត់ផ្តង់ប្រភពធនធានមនុស្ស និងគោលរបបនានា រីឯគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកំលាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ធានាផ្តត់ផ្តង់ប្រភពសម្ភារៈ មធ្យោបាយ គ្រឿងបំពាក់ និងថវិកាផ្សេងៗ សំរាប់ដំណើរការការងារ ការហ្វឹកហ្វឺន និងកិច្ចការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

ម.ជ.រ.ប.ក. អាចទំនាក់ទំនងរកប្រភពជំនួយពីបណ្តាប្រទេសផ្សេងៗ និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងរកប្រាក់កំរៃពីសេវាកម្មផ្សេងៗ ផ្តល់ដោយអង្គការសាធារណៈ និងឯកជន ។

ឯកូតទី ៥
អចសានុប្បញ្ញត្តិ

មាត្រា ១៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៩.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ប្រធានគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

